ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ
លេខ ១៤៣៤០ អពដ

# សេចក្ដីបំភ្លឺ

I- ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា សារព័ត៌មានក្នុងស្រុកមួយចំនួន បានចុះផ្សាយអត្ថបទក្រោមចំណងជើងថា ***"វិទ្យុអាស៊ីសេរី និងVOA គ្រាន់តែជួលម៉ោងផ្សាយ មិនបាច់បង់ពន្ធទេ"***។

អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបំភ្លឺជូនសារព័ត៌មាន ក៏ដូចជាសាធារណជនទាំងអស់ មេត្តាជ្រាបថា អនុលោមតាមមាត្រា ១០១ នៃច្បាប់ស្ដីពីសារពើពន្ធ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧ និងវិសោធនកម្មជាបន្តបន្ទាប់ និងប្រកាសលេខ ១១៣៩ សហវ.ប្រក ចុះថ្ងៃទី០៩ ខែតុលា ឆ្នាំ២០១៤ ស្ដីពីការចុះបញ្ជីពន្ធដារ ដែលត្រូវបានកែសម្រួលដោយប្រកាសលេខ ៤៩៦ សហវ ចុះថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្ដីពីការចុះបញ្ជីពន្ធដារ បុគ្គលទាំងឡាយត្រូវទៅចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធក្នុងកំឡុង ១៥ថ្ងៃ ក្រោយពីបុគ្គលនោះចាប់ផ្ដើមធ្វើសកម្មភាពសេដ្ឋកិច្ច។ មាត្រា៨ នៃច្បាប់ដដែលចែងថា "**សកម្មភាពសេដ្ឋកិច្ច**" សំដៅដល់សកម្មភាពរបស់បុគ្គលដែលធ្វើជានិច្ចកាលជាប់បន្តឬមួយដងមួយគ្រា ដើម្បីរកឬមិនរកចំណេញ ក្នុងការផ្គត់ផ្គង់ឬមានបំណង ផ្គត់ផ្គង់ទំនិញឬសេវា ឱ្យបុគ្គលដទៃក្នុងគោលដៅដើម្បីបានអត្ថប្រយោជន៍អ្វីមួយ ហើយមាត្រា៥៦ នៃច្បាប់ដដែលនេះ បានកំណត់និយមន័យនៃពាក្យ "***សេវា***" ដែលសំដៅដល់ការផ្ដល់អ្វីមួយដែលមានតម្លៃក្រៅពីទ្រព្យរូបី ដីធ្លី និងប្រាក់កាស។

ផ្អែកតាមបទប្បញ្ញត្តិច្បាប់ដូចជម្រាបជូនខាងលើ វិទ្យុទាំងពីរនេះដែលមានការិយាល័យតំណាងរបស់ខ្លួន មានទីតាំងត្រឹមត្រូវ ដើម្បីរៀបចំការផ្សាយសារព័ត៌មានរបស់វិទ្យុ ត្រូវចាត់ទុកថាជាអ្នកជាប់ពន្ធនិវាសនជនដែលធ្វើការផ្គត់ផ្គង់សេវាក្នុងព្រះរាជាណាចក្រកម្ពុជា ហើយត្រូវមានកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងបង់ពន្ធ-អាករនានា ស្របតាមបទប្បញ្ញត្តិច្បាប់ជាធរមាន បើទោះជាការផ្សាយនោះធ្វើឡើងតាមរយៈការទិញម៉ោងផ្សព្វផ្សាយពីវិទ្យុដទៃក៏ដោយ។

II- ទន្ទឹមនឹងនេះដែរ មានសារព័ត៌មានក្នុងស្រុកមួយចំនួនបានលើកឡើងថា ***"ចំណាត់ការពន្ធដារនាពេលថ្មីៗកន្លងមកនេះចំពោះសហគ្រាសមួយចំនួន រួមទាំងសហគ្រាសដែលប្រកបអាជីវកម្មក្នុងវិស័យសារព័ត៌មាន និងអង្គការសង្គមស៊ីវិល គឺមានចរិតនយោបាយ"***។

ឆ្លើយតបទៅនឹងការលើកឡើងនេះ អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការបំភ្លឺបន្ថែមជូនសាធារណជនថា អគ្គនាយកដ្ឋានពន្ធដារមានបេសកកម្មប្រមូលចំណូលពន្ធផ្ទៃក្នុង ស្របតាមច្បាប់ស្ដីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងសម្រាប់ឆ្នាំនីមួយៗ ដើម្បីទ្រទ្រង់ការចំណាយលើការផ្ដល់សេវាសាធារណៈ ប្រាក់បៀវត្សរបស់មន្ត្រីរាជការ កងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ និងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធនានា ជាដើម។

ដើម្បីពង្រឹងការអនុវត្តការប្រមូលពន្ធប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព តម្លាភាព សមភាព និងអស់សក្ដានុពល អគ្គនាយកដ្ឋានបាននិងកំពុងធ្វើការកែទម្រង់ តាមរយៈការពង្រឹងការអនុវត្តច្បាប់ ការពង្រឹងនិងកែលម្អរដ្ឋបាលសារពើពន្ធ ដោយផ្អែកលើយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ជាត្រីវិស័យ និងផ្ដោតលើមុខងារសំខាន់ៗ ដែលក្នុងនោះ ការចុះបញ្ជីពន្ធដារ ការផ្ដល់សេវាអ្នកជាប់ពន្ធ ការចាត់ចែងលិខិតប្រកាស ការធ្វើសវនកម្ម ការប្រមូលបំណុលពន្ធនិងបណ្ដឹងតវ៉ា ដែលជាចំណុចអាទិភាពដ៏សំខាន់ក្នុងការកែទម្រង់។

ក្នុងន័យនេះ ប្រព័ន្ធចុះបញ្ជីពន្ធដារថ្មីមួយដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ត្រឹមត្រូវ ច្បាស់លាស់ ស្របតាមបទប្បញ្ញត្តិច្បាប់ ត្រូវបានបង្កើតឡើងដើម្បីងាយស្រួលដល់រដ្ឋបាលសារពើពន្ធក្នុងការគ្រប់គ្រង តាមដានការគោរពកាតព្វកិច្ចសារពើពន្ធរបស់អ្នកជាប់ពន្ធ។


អាគារកែងមហាវិថី សហព័ន្ធរុស្ស៊ី(១១០)និង ម៉ៅសេទុង(២៤៥), សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ (+855) 23 886 708 ទូរសារ: (+855)23 886 700, Email: gdt@tax.gov.kh, Website: www.tax.gov.kh

លើផ្នែកការងារសវនកម្មវិញ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងធ្វើសវនកម្មយ៉ាងសកម្ម លើគ្រប់សហគ្រាសទាំងអស់ រួមបញ្ចូលទាំងសហគ្រាសប្រកបអាជីវកម្មក្នុងវិស័យសារព័ត៌មាន និងទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនិងអន្តរជាតិផងដែរ ព្រោះថា កាអនុវត្តប្រមូលពន្ធតាមរបបស្វ័យប្រកាស អ្នកជាប់ពន្ធមានកាតព្វកិច្ចដាក់លិខិតប្រកាសពន្ធ គណនាប្រាក់ពន្ធ និងបង់ពន្ធដោយខ្លួនឯង។ ដូច្នេះ ការធ្វើសវនកម្មគឺជាយន្តការតែមួយគត់មិនអាចខ្វះបាន និងជាម៉ែត្រសម្រាប់វាស់វែងអំពីភាពត្រឹមត្រូវ និងសម្រាប់តាមដានត្រួតពិនិត្យអំពីសុចរិតភាព និងភាពស្មោះត្រង់របស់អ្នកជាប់ពន្ធ ដើម្បីទប់ស្កាត់ការគេចវេះពន្ធ ព្រមទាំងជាយន្តការជំរុញ និងពង្រឹងអនុលោមភាពសារពើពន្ធរបស់អ្នកជាប់ពន្ធ និងធ្វើឱ្យមានតម្លាភាព សមភាព ដែលនាំទៅដល់ការប្រកួតប្រជែងប្រកបដោយស្មើភាពគ្នារវាងបណ្តាធុរកិច្ចនានា។

ជារៀងរាល់ឆ្នាំ អគ្គនាយកដ្ឋានពន្ធដារបានដាក់កម្មវិធីសវនកម្មសហគ្រាសអ្នកជាប់ពន្ធលើគ្រប់វិស័យទាំងអស់ រួមទាំងវិស័យសារព័ត៌មាន និងអង្គការសង្គមស៊ីវិល ដែលជាលទ្ធផល ក្នុងរយៈពេលបួនឆ្នាំចុងក្រោយ ពោលគឺចាប់ពីឆ្នាំ២០១៤ ដល់ ឆ្នាំ២០១៧ អគ្គនាយកដ្ឋានពន្ធដារបានធ្វើសវនកម្មលើសហគ្រាស**ចំនួន ៩ ៤០៨ មានប្រាក់ពន្ធសរុបចំនួន ៨ ០០០ ពាន់លានរៀល (ស្មើនឹង ២ ០០០ លានដុល្លារអាមេរិក) ក្នុងនោះ នៅឆ្នាំ២០១៤ បានធ្វើសវនកម្ម ចំនួន ១ ០៤០ សហគ្រាស មានប្រាក់ពន្ធចំនួន ៤៣៩ ០០០ លានរៀល (ស្មើនឹង ១០៩ លានដុល្លារអាមេរិក) ឆ្នាំ២០១៥ ចំនួន ២ ០១៨ សហគ្រាស មានប្រាក់ពន្ធចំនួន ១ ៨២១ ៤០០ លានរៀល (ស្មើនឹង៤៥៥ លានដុល្លារអាមេរិក) ឆ្នាំ២០១៦ ចំនួន ៣ ៦៩០ សហគ្រាស មានប្រាក់ពន្ធចំនួន ២ ៩៤០ ៦០០ លានរៀល (ស្មើនឹង ៧៣៥ លានដុល្លារអាមេរិក) និងរយៈពេលប្រាំពីរខែដើមឆ្នាំ២០១៧ ចំនួន ១ ៨៣៦ សហគ្រាស មានប្រាក់ពន្ធចំនួន ២ ៤៤៩ ១៤០ លានរៀល (ស្មើនឹង ៦១២ លានដុល្លារអាមេរិក)។**

បន្ថែមពីលើនេះទៀត មាត្រា៩២ និងមាត្រា១១៧ នៃច្បាប់ស្តីពីសារពើពន្ធ បានផ្តល់សិទ្ធិជូនរដ្ឋបាលសារពើពន្ធ ក្នុងការកំណត់មូលដ្ឋានកំណត់ពន្ធឡើងវិញ ដែលការកំណត់ពន្ធនេះអាចធ្វើឡើងក្នុងរយៈពេលរហូតដល់ ១០ឆ្នាំ ក្រោយកាលបរិច្ឆេទដែលតម្រូវឱ្យដាក់លិខិតប្រកាសសារពើពន្ធ។ តាមរយៈច្បាប់ដដែលនេះ រដ្ឋបាលសារពើពន្ធអាចតម្រូវឱ្យអ្នកជាប់ពន្ធផ្តល់នូវបញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការ ដែលអ្នកជាប់ពន្ធត្រូវកាន់រក្សាទុកនិងផ្តល់ជូនរដ្ឋបាលសារពើពន្ធ ហើយថែមទាំងមានសិទ្ធិទាមទារឱ្យអ្នកជាប់ពន្ធ ឬតតិយជន រួមទាំង ស្ថាប័នរដ្ឋទាំងឡាយផ្តល់នូវព័ត៌មានទាក់ទិននឹងអ្នកជាប់ពន្ធទៀតផង។ លើសពីនេះទៀត ក្នុងផ្នែកទី៦ នៃជំពូកទី៥ ក៏បានផ្តល់អំណាចដល់រដ្ឋបាលសារពើពន្ធក្នុងការប្រមូលប្រាក់ពន្ធ រួមមាន (១) សិទ្ធិឃុំគ្រងលើទ្រព្យសម្បត្តិរបស់អ្នកជាប់ពន្ធ (២) ការចេញលិខិតជូនដំណឹងរំលឹកការទារបំណុលពន្ធ (៣) ការរឹបអូសទ្រព្យសម្បត្តិអ្នកជាប់ពន្ធ (៤) ការឃាត់ទុកគណនីធនាគារ (៥)ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល និង (៥) ការទុកជាមោឃៈនូវលិខិតអនុញ្ញាតនិងអាជ្ញាប័ណ្ណនានា។

ដូច្នេះ អគ្គនាយកដ្ឋានពន្ធដារសូមបដិសេធចំពោះការលើកឡើងថា "ចំណាត់ការពន្ធដារនាពេលថ្មីៗកន្លងមកនេះចំពោះសហគ្រាសមួយចំនួន រួមទាំងសហគ្រាសដែលប្រកបអាជីវកម្មក្នុងវិស័យសារព័ត៌មាន និងទាំងអង្គការសង្គមស៊ីវិល គឺមានចរិតនយោបាយ" ពីព្រោះការលើកឡើងនេះ មិនមែនជាការពិត។

អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា សាធារណជន ក៏ដូចជាអ្នកជាប់ពន្ធទូទៅមេត្តាជ្រាប និងចូលរួមសហការអនុវត្តបំពេញកាតព្វកិច្ចសារពើពន្ធស្របតាមច្បាប់និងបទប្បញ្ញត្តិស្តីពីពន្ធដារជាធរមានឱ្យបានខ្ជាប់ខ្ជួន។

រាជធានីភ្នំពេញ, ថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧

**អគ្គនាយកដ្ឋានពន្ធដារ**